ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៤

# អនុក្រឹត្យ លេខ ០៤ អនក្រ
# ស្តីពីការកំណត់ភារកិច្ច និង សមត្ថកិច្ចរបស់
# ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ១៥ អ.ន.ក្រ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់នៃការងារនីតិសម្បទា និង អភិវឌ្ឍន៍នៅព្រះរាជាណាចក្រកម្ពុជា

## សំរេច

**ប្រការ ១ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍មានភារកិច្ច បំពេញមុខនាទីក្នុងការសំរបសំរួលការងាររបស់បណ្តាក្រសួង និង ស្ថាប័ន នានាដែលមានសមត្ថកិច្ច និង ការពាក់ព័ន្ធក្នុងការលើកកម្មវិធី និង តំរោងស្តារ និង កសាងប្រទេស ព្រមទាំងក្នុងការទទួលជំនួយបរទេស និង ក្នុងការធ្វើវិនិយោគ ទាំងសាធារណៈ ទាំងឯកជន ។ ភារកិច្ចសំរបសំរួលការងារនេះ សំខាន់គឺសំដៅ :

ទី ១ : លើកលំជាប់អាទិភាពនៃតម្រូវការរបស់ប្រទេសជាតិក្នុងការធ្វើនីតិសម្បទា និង អភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និង សំរាប់រយៈពេលខ្លី រយៈពេលមធ្យម ព្រមទាំងរយៈពេលវែង ដើម្បីបង្កើតឡើងនូវគោលគំនិត និង កម្មវិធីរួមស្តីពីការងារនីតិសម្បទា និង អភិវឌ្ឍន៍ ។ កម្មវិធីនេះត្រូវមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡា

និង ស៊ីសង្វាក់គ្នា ។ រាល់គំរោងផ្សេងៗ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនេះ ។

ទី ២ : តំរង់ទិសក្នុងការបែងចែក និង ផ្គត់ផ្គង់ធនធាននៅក្នុងប្រទេស និង ធនធានដែលបានមកពីក្រៅប្រទេស ដើម្បីទីតិសម្បទា និង អភិវឌ្ឍន៍ប្រទេស ។ ជាក់ស្តែង គឺសំរបសំរួលការទទួលជំនួយ ទ្វេភាគី ពហុភាគី និង ពីអង្គការអន្តរជាតិនានា អោយស្របតាមសេចក្តីត្រូវការរបស់ប្រទេស ហើយសំរបសំរួលការទទួលជំនួយនេះជាមួយនឹងកិច្ចការវិនិយោគឯកជន ។ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទីតិសម្បទា និង អភិវឌ្ឍន៍ ត្រូវតាមដាន និង ធ្វើវិចារណកម្មលើការ បែងចែកនិងផ្គត់ផ្គង់ធនធាន ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការងារនេះ ។

ប្រការ ២ : សមត្ថកិច្ចរបស់ការងារខាងលើនេះ មានការពាក់ព័ន្ធទៅនឹងផ្នែកដូចតទៅ ÷

ទី ១ : ការស្តារ និង សាងសង់ហេដ្ឋារចនាសម្ព័ន្ធ សំរាប់បំរើអោយ ផលិតកម្ម កសិកម្ម និង ឧស្សាហកម្ម ទេសចរ ការដឹកជញ្ជូន សេវាកម្មនានា និង ការអភិវឌ្ឍន៍ជនបទ ព្រមទាំងសំរាប់បំរើសុខមាលភាពរបស់ប្រជារាស្ត្រទូទៅ ។

ទី ២ : ការធ្វើទីតិសម្បទា និង អភិវឌ្ឍន៍ធនធានមនុស្ស ដែលទាក់ទិនទៅនឹងការបំប៉នសុខភាព ពង្រីកចំណេះដឹង ចំណេះធ្វើ និង ការផ្លាស់ប្តូរឥរិយាបថអោយស្របតាមយន្តការសេដ្ឋកិច្ចទីផ្សារសេរី ។

ទី ៣ : ការកែប្រែរចនាសម្ព័ន្ធរដ្ឋបាល ព្រមទាំងការធ្វើ ឬ កែលំអលិខិតបទដ្ឋាន ដែលត្រូវបំរើ សន្តិសុខ ស្ថេរភាពសង្គម និង សុខមាលភាពរបស់ប្រជារាស្ត្រ និង ក្នុងគោលបំណងបង្កើតបរិដ្ឋានសង្គម - សេដ្ឋកិច្ចមួយ ដែលបំរើអោយយន្តការទីផ្សារដោយរដ្ឋ និង ឯកជន ត្រូវប្រកាន់តួនាទីជាដៃគូ និង ជាគូសន្ទនានឹងគ្នា ហើយក្នុងនេះរដ្ឋត្រូវស្ថិតនៅជាយុទ្ធសាស្ត្រវិទូ នៃការអភិវឌ្ឍន៍ ។

ទី ៤ : ការអភិវឌ្ឍន៍ធនធានធម្មជាតិ ហើយនិងការគ្រប់គ្រង និង ការពារបរិដ្ឋាន ។

ទី ៥ : ការចូលរួមគ្រប់គ្រងកិច្ចការវិនិយោគឯកជន ។

ទី ៦ : ការទាក់ទងជាមួយប្រទេស និង អង្គការអន្តរជាតិអ្នកផ្តល់ជំនួយនានា ពិសេសក្នុងក្របខ័ណ្ឌគណៈកម្មាធិការអន្តរជាតិសំរាប់ស្តារកម្ពុជាឡើងវិញ ( ICORC ) និង កម្មវិធីអភិវឌ្ឍន៍ នៃសហប្រជាជាតិ ( UNDP ) ដើម្បីធ្វើអោយគេយល់ជ្រួតជ្រាប អំពីគោលគំនិត និង បណ្តាអាទិភាព នៃកម្មវិធីទីតិសម្បទា និង អភិវឌ្ឍន៍ប្រទេសព្រមទាំងសំរបសំរួលការទទួលនិង បែងចែកជំនួយអន្តរជាតិក្នុងគោលបំណង

ប្រើប្រាស់ជំនួយទាំងនេះអោយមានប្រសិទ្ធភាព និង ស្របតាមសេចក្តីត្រូវការរបស់ប្រទេសជាតិ ។

**ប្រការ ៣:** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍ អនុវត្តភារកិច្ចដូចមានចែងខាងលើ ស្របតាមសមត្ថកិច្ចរបស់ខ្លួន និង ស្របតាមភារបំពេញមុខងារក្នុងការរួមគ្រប់គ្រងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ “ ក.អ.ក ” ហើយនឹងមុខងារក្នុងការដឹកនាំការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការជាតិសំរាប់នីតិសម្បទា និង អភិវឌ្ឍន៍ ហៅកាត់ “ គជនា ” ព្រមទាំងការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការជាតិវិនិយោគ ហៅកាត់ “ គជវិ ” ក្នុងក្របខ័ណ្ឌអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានរយោងខាងលើ ។ ជាមួយគ្នានេះ ក្នុងករណីចាំបាច់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍ ត្រូវចូលរួមដោយផ្ទាល់ ក្នុងកិច្ចសំរបសំរួលការងាររបស់បណ្តាក្រសួង និង ស្ថាប័នផ្សេង ៗ ព្រមទាំងជាមួយបរទេសស្របតាមការងារជាក់ស្តែង ដែលមានការពាក់ព័ន្ធទៅនឹងកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍ ។

**ប្រការ ៤ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍ អាចមានឧបការី និង អ្នកជំនាញការមួយចំនួន សំរាប់ជាជំនួយការ និង ទីប្រឹក្សា ដើម្បីសំរេចបានប្រកបដោយគុណភាព និង ប្រសិទ្ធភាព នូវភារកិច្ចដូចបានកំណត់ខាងលើ ។

**ប្រការ ៥ :** រាល់បទបញ្ញត្តិពីមុន ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** រាល់ក្រសួង និង ស្ថាប័នពាក់ព័ន្ធនានា និង ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ដោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា នេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |